# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

...............

សាលាឧទ្ធរណ៍ភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៣៤៧ / ២៥.៤.២០១១
សាលដីកា
លេខ: ៨៦ ក្រ.III.ស/៣០.១០.២០១៣

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៣ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធាន

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីធ្វើការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៣៤៧ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១១ រវាង៖

ជនជាប់ចោទឈ្មោះ [redacted] ខែម ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ មុខរបរៈធ្វើស្រែ ទីលំនៅកំណើត និង ទីលំនៅមុនចាប់ខ្លួន [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ។

<u>ជាប់ចោទពីបទ:</u> ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅ ភូមិក្រាំងស្វាយ ឃុំធម្មតាអរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោស តាមមាត្រា ៣ នៃច្បាប់ស្តានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ២៧ឆ្នាំ ជាតិខ្មែរ មុខរបរៈធ្វើស្រែ បច្ចុប្បន្ន [redacted]

ជនរងគ្រោះឈ្មោះ [redacted] យ៉ុន ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ មុខរបរៈធ្វើស្រែ បច្ចុប្បន្នរស់នៅ [redacted]

## ដំណើររឿងមានដូចតទៅ៖

កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៩ វេលាម៉ោង៧ និង៣០នាទីយប់ នៅចំណុចមុខផ្ទះរបស់ឈ្មោះ [redacted] ខែម ស្ថិតនៅភូមិក្រាំងស្វាយ ឃុំធម្មតាអរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ មានករណីសម្លាប់មនុស្ស បង្ក ឡើងដោយជនសង្ស័យឈ្មោះ [redacted] ខែម ក្នុងខណៈពេលដែលជនរងគ្រោះឈ្មោះ [redacted] យ៉ុន ត្រឡប់មកពីដើរ លេងវិញ លុះដល់ពេលដើរមកដល់មុខផ្ទះឈ្មោះ [redacted] ខែម ពេលនោះជនសង្ស័យបានយកកាំបិតផ្គាក់ផ្លែងុក កាប់លើឈ្មោះ [redacted] យ៉ុន ចំនួនពីរកាំបិតចំពីក្រោយ បណ្តាលឲ្យដួលស្លាប់តែម្តង ក្រោយពេលដែលជន សង្ស័យសម្លាប់ជនរងគ្រោះហើយ ជនសង្ស័យបានរត់គេចខ្លួនបាត់តែម្តង។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ០២ (ង) ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ របស់សាលា ដំបូងខេត្តកំពង់ស្ពឺ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- ផ្តន្ទាទោសឈ្មោះ [redacted] ខែម ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ ទីលំនៅកំណើត និងសព្វថ្ងៃ [redacted] សាសនាព្រះពុទ្ធ មុខរបរៈធ្វើស្រែ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ដាក់ពន្ធនាគារតម្រូវឲ្យធ្វើការកំណត់ ១៦ឆ្នាំ (ដប់ប្រាំមួយឆ្នាំ) គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ពីបទ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅ ភូមិក្រាំងស្វាយ ឃុំធម្មតាអរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៩, បទល្មើស ដែលមានចែង និងឲ្យផ្តន្ទាទោស តាមមាត្រា ៣ នៃច្បាប់ស្តានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២- សាលក្រមនេះ ប្រកាសជាសាធារណៈ នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១១ របស់លោកស្រី [redacted] ម៉េងអ៊ាម ជាមេធាវីទទួល សិទ្ធិប្តឹងពីជនជាប់ចោទឈ្មោះ [redacted] ខែម ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ០២ (ង) ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ត្រង់ចំណុចផ្តន្ទាទោសនៃសេចក្តីសម្រេច ។

បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

បានឃើញ របាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍ ។

## នាំពេលសវនាការ

ប្រធានក្រុមប្រឹក្សា បញ្ជាក់អង្គហេតុរឿងជូនអង្គសវនាការ

ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] ខែម បានឆ្លើយនៅសាលាដំបូងខេត្តកំពង់ស្ពឺ។ ៤

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សំណាង ឆ្លើយថា ខ្លួនត្រូវជាប្រពន្ធជនរងគ្រោះ និងត្រូវជាប្អូនរបស់ជនជាប់ចោទ ខ្លួនសំណូមពរសុំបន្ធូរបន្ថយទោសដល់ជនជាប់ចោទ ព្រោះឪពុកម្តាយខ្លួនចាស់ៗហើយ។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

សុំក្រុមប្រឹក្សាពិនិត្យ និងពិចារណាតាមច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

កូនក្តីខ្លួនឈ្មោះ [redacted] ខែម ត្រូវបានសាលាដំបូងសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន១៦ឆ្នាំ ពីបទឃាតកម្មគិតទុកជាមុន តាមមាត្រា៣ នៃច្បាប់ស្តានទម្ងន់ទោសនៃបទឧក្រិដ្ឋ។ ក្នុងរឿងនេះ កូនក្តីខ្លួនបានបញ្ជាក់ថា គាត់ពិតជាបានប្រព្រឹត្តមែន ដោយកន្លងមកគាត់ធ្លាប់មានទំនាស់ជាមួយគ្នាជាច្រើនលើកមកហើយ ហើយថ្ងៃកើតហេតុមានការប្រតាយប្រតប់គ្នា ក្រោយមកកូនក្តីខ្លួនបានត្រៀមកាំបិតផ្គាក់ត្រៀមចាំកាប់ជនរង គ្រោះ ពេលកាប់ជនរងគ្រោះរួច បានរត់គេចទៅភ្នំ៥ថ្ងៃ បន្ទាប់មកទៅធ្វើការជាកម្មករនៅកំពង់សោម បន្ទាប់មកក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនបាន សូមលោកប្រធានពិចារណាលើមាត្រា៩៥ និងមាត្រា២០០ នៃក្រមព្រហ្មទណ្ឌ និងសូមបន្ធូរបន្ថយទោសដល់កូនក្តីខ្លួន តាមមាត្រា ៩៣, ហើយរឿងនេះ ដើមបណ្តឹងរដ្ឋប្បវេណីគាត់បានសំណូមពរសុំឲ្យលោកប្រធានបន្ធូរបន្ថយទោសដល់បងគាត់ [redacted] ខែម, សូមក្រុមប្រឹក្សាពិចារណា។

ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី,

ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ,

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

## សភាព្រហ្មទណ្ឌ

## យល់ឃើញថា៖

១. បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១១ របស់លោកស្រី [redacted] ម៉េងអ៊ីម ជាមេធាវីទទួលសិទ្ធិពីជនជាប់ចោទឈ្មោះ [redacted] ខែម ធ្វើត្រឹមត្រូវ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. តាមចម្លើយជនជាប់ចោទនៅចៅក្រមស៊ើបសួរ និងនៅសវនាការថា នៅថ្ងៃកើតហេតុមានការស៊ី ផឹក, ពេលនោះជនរងគ្រោះឈ្មោះ [redacted] យ៉ុន ជាប្អូនថ្លៃខ្លួន និយាយមិនត្រូវគ្នា ក៏មានការទាស់សម្តីគ្នា ហើយជនរងគ្រោះប្រាននខ្លួនផ្ទប់នឹងសសរផ្ទះ និងវាយខ្លួនមួយដៃថែមទៀត ក៏មានការប្រតាយប្រតប់គ្នាកើតឡើង។ ជនរងគ្រោះដួលក៏យកកាំបិតពីក្រោមគ្រែមកបម្រុងកាប់ខ្លួន តែត្រូវខ្លួនចាប់កាំបិតបាន កាប់វិញត្រូវកជិតដាច់ និងកាប់ថែមមួយកាំបិតទៀតចំកដៃ។៚

ឯនៅសមត្ថកិច្ចនគរបាល និងនៅអយ្យការ ជនជាប់ចោទឆ្លើយថា កន្លងទៅជនរងគ្រោះបានជេរ និងវាយខ្លួនផ្ទប់ទៅនឹងសសរផ្ទះ ខ្លួនឲ្យវាសុំទោសខ្លួន តែពីមួយថ្ងៃទៅមួយថ្ងៃ វាមិនព្រមសុំទោសខ្លួនសោះ ធ្វើឲ្យខ្លួនមានកំហឹងខ្លាំងឡើងៗ ទើបនៅថ្ងៃកើតហេតុ ខ្លួនបានយកកាំបិតផ្គាក់កាប់ទៅលើជនរងគ្រោះតែម្តង។

៣. មានភស្តុតាងបញ្ជាក់ពិរុទ្ធភាព លើជនជាប់ចោទពីបទ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅ ភូមិក្រាំងស្វាយ ឃុំធម្មតាអរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោស តាមមាត្រា ៣ នៃច្បាប់ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

៤. សំអាងហេតុ និងសេចក្តីវិនិច្ឆ័យ នៃសាលក្រមព្រហ្មទណ្ឌ ០២ (ង) ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តកំពង់ស្ពឺ មានភាពច្បាស់លាស់ និងត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១. ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១១ របស់លោកស្រី [redacted] ម៉េងអ៊ាម ជាមេធាវីទទួលសិទ្ធិ ពីជនជាប់ចោទឈ្មោះ [redacted] ខែម ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធ ចោល ដោយផ្ទុយនឹងគតិច្បាប់។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០២ (ង) ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ទុកជាបានការពេញទាំងមូល។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៣ ប្រកាសជា សាធារណៈ នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៣ ចំពោះមុខមេធាវីការពារជនជាប់ចោទ, កំបាំងមុខ ជនជាប់ចោទ, បើកផ្លូវតវ៉ាតាមកំណត់ច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មក មន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។ល។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

.................................................................................................

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥

ក្រឡាបញ្ជី